## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ៣៤.ស.សរ

## សេចក្តីសំរេច

### ស្តីពី

### ការបង្កើតគណៈកម្មការដឹកនាំគំរោងរៀបចំតំបន់អភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក និងគម្រោងអភិវឌ្ឍន៍ភូមិកំពង់ភ្លុកប្រកបដោយចីរភាព

៚ ✻ ៚

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិអប្សរា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ *នស/រកត/០៧០៤/១២៤* ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ *០២/នស/៩៤ ចុះថ្ងៃទី២០* ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ *នស/រកម/០១៩៦/០៩* ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ *នស/រកត/០២៩៥/១២* ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរ ដើម្បីការពារ និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ *នស/រកត/០១៩៩/១៨* ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពី ការកែសម្រួល បទប្បញ្ញត្តិមួយចំនួន នៃព្រះរាជក្រឹត្យលេខ *នស/រកត/០២៩៥/១២* ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរអប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ *នស/រកត/០៩០៤/២៦៧* ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពី ការកែសំរួលមាត្រា៤ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ *នស/រកត/០១៩៩/១៨* ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពី ការកែសម្រួល បទបញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ *នស/រកត/ ០២៩៥/១២* ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ *១៥ អនក្រ.បក* ចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ២០០៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ *៩៦ អនក្រ.បក* ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសំរួលមាត្រា៦ និងមាត្រា១៤ នៃអនុក្រឹត្យលេខ *១៥ អនក្រ.បក* ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- សេចក្តីសម្រេចលេខ ១៤ សសរ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០០០៨ ស្តីពីការតែងតាំងប្រធានគំរោងរបស់អាជ្ញាធរអប្សរា
- យោងតាមការចាំបាច់នៃការងាររបស់អាជ្ញាធរអប្សរា ។

## ស ម្រេ ច

**ប្រការ ១ :** បង្កើតគណៈកម្មការដឹកនាំគំរោងរៀបចំតំបន់អភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក និងគំរោងអភិវឌ្ឍន៍ភូមិកំពង់ភ្លុកប្រកបដោយចីរភាព ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ម៉ុន ណារិទ្ធ** | អគ្គនាយក អាជ្ញាធរជាតិអប្សរា | ប្រធាន |
| ២-ឯកឧត្តម **ឈឹម ចាន់ណារ៉ា** | ទទួលបន្ទុកការងារគ្រប់គ្រងព្រៃឈើ | សមាជិក |
| ៣-លោក **ឃួន ឃុនណៃយ** | ប្រធាននាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យាទី២ | សមាជិក |
| ៤-លោកស្រី **ឆេត ទត្ត** | ប្រធាននាយកដ្ឋាននគរូបនីយកម្ម និងអភិវឌ្ឍន៍តំបន់សៀមរាប-អង្គរ | សមាជិក |
| ៥-លោកស្រី **ចៅ ស៊ុនគិរិយា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ | សមាជិក |
| ៦-លោក **ហង់ ពៅ** | ប្រធានាយកដ្ឋានទឹក និងព្រៃឈើ | សមាជិក |
| ៧-លោក **តាន់ ម៉ិនស៊ុយ** | ប្រធាននាយកដ្ឋានប្រជាសាស្ត្រ និងការអភិវឌ្ឍ | សមាជិក |

**ប្រការ ២ :** គណៈកម្មការមានភារកិច្ច :

-ដឹកនាំ ត្រួតពិនិត្យ និងផ្តល់យោបល់លើឯកសារពាក់ព័ន្ធនឹងការរៀបចំតំបន់អភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក និងគំរោងអភិវឌ្ឍន៍ភូមិកំពង់ភ្លុកប្រកបដោយចីរភាព ដែលសិក្សា និងរៀបចំដោយក្រុមការងារបច្ចេកទេស។

-ធ្វើការពិភាក្សា និងលើកយោបល់ជូន ឯកឧត្តមប្រធានអាជ្ញាធរជាតិអប្សរា ដើម្បីពិនិត្យសម្រេច។

**ប្រការ ៣ :** ក្រោយពីបានការឯកភាពរបស់ ឯកឧត្តមប្រធានអាជ្ញាធរជាតិអប្សរារួចហើយ គណៈកម្មការត្រូវធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរខេត្តសៀមរាប ដើម្បីអនុវត្តគំរោងនេះឱ្យបានរលូន។

**ប្រការ ៤ :** ឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ០៦ ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

**សុខ អាន**

**កន្លែងទទួល :**

-អគ្គនាយកដ្ឋាន នៃអាជ្ញាធរជាតិអប្សរា

-ដូចប្រការ ៤ *"ដើម្បីអនុវត្ត"*

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ